77
1

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី ៣៣*៥៥

លេខៈ ៥៩

ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០២ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ១៧៨ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤

ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៊ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៣-លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៤-លោក | ជីវ | កេង | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |
| លោក | **សុខ** | **ទៅ** | ក្រឡាបញ្ជី |
| | តំណាងមហាអយ្យការ | | |
| លោក | **ឈួន** | **ចាន់ថា** | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨៥ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ**សោម ចិន្ត** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ មានទីលំនៅបច្ចុប្បន្ន ភូមិស្រះកែវ ឃុំរកាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

មានមេធាវីលោក ហេង ពូន ។

ចុងចម្លើយឈ្មោះ**ចិត ចាង** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៥៦ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្នភូមិស្រះកែវ ឃុំរកាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

<u>**កម្មវត្ថុបណ្តឹង**</u> : ប្តឹងទាមទារសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាន និងរុះរើសំណង់ចេញពីដីទំនាស់

បានឃើញបណ្តឹងសាទុក្ខចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ របស់ឈ្មោះប៉ិច ហុង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៥៩ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩២ របស់ភាគីដើមចោទឈ្មោះសោម ទិត្យ បានបញ្ជាក់ថា ដីទំនាស់ដែលមានទីតាំងស្ថិតនៅភូមិស្រះកែវ ឃុំរំាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ជាដីកម្មសិទ្ធិរបស់ខ្លួន ដោយមានលិខិតប្រគល់ដីរបស់លោកប៉ែន វុធ អតីតៈប្រធានឃុំរំាំងចាស់ លេខ០៧២ ចុះថ្ងៃទី០១-០៤-១៩៨៦ និងប័ណ្ណកម្មសិទ្ធិលេខ ០០០៨១ ចុះថ្ងៃទី២៥-០១-១៩៩២ របស់សុរិយោដីខេត្តកំពង់ស្ពឺ ជាសំអាង ។

អំពីប្រវត្តិដីទំនាស់នេះ កាលពីឆ្នាំ១៩៨៦ មានខ្លួន,ឈ្មោះចោង លឹម ,ឈ្មោះជា ឧត្តរូ, ឈ្មោះស៊ុន ស៊ុយ បានរកស៊ីចូលហ៊ុនគ្នាធ្វើអាជីវកម្មអារឈើ ដោយភាគីខ្លួនជាអ្នកមានដីទីតាំងសំណង់ រីឯ៣នាក់ទៀត ជាអ្នកមានម៉ាស៊ីនអារឈើ ដោយគិតភាគហ៊ុនជា៤ចំណែកស្មើគ្នា ។ ក្រោយមានអាជីវកម្មមួយរយៈ ក៏មានការបែកបាក់រវាងឈ្មោះចោង លឹម, ឈ្មោះជា ឧត្តរូ,ឈ្មោះស៊ុន ស៊ុយ ហើយពេលនោះ ឈ្មោះចោង លឹម និងឈ្មោះជា ឧត្តរូ ក៏បានដកភាគហ៊ុនវិញ នៅសល់តែឈ្មោះស៊ុន ស៊ុយ បន្តការរកស៊ី ។ ក្រោយមកទៀតឈ្មោះស៊ុន ស៊ុយ ក៏បានលក់ម៉ាស៊ីនអារឈើនេះ ទៅឱ្យឈ្មោះប៉ិចហុង ក្នុងតំលៃ៩តំឡឹងមាស តែដោយមានទំនាស់ពីគុណភាពម៉ាស៊ីន តំលៃព្រមព្រៀងធ្លាក់មកត្រឹម៨តំឡឹងកន្លះ ។ ពេលឈ្មោះប៉ិច ហុង ទិញម៉ាស៊ីនដើម្បីបន្តអាជីវកម្ម ពីឈ្មោះស៊ុន ស៊ុយ បានឱ្យប្រាក់ចំណែករបស់ខ្លួនក្នុងមួយខែ គឺ ១៥.០០០៛ ។ លុះក្រោយមកនៅដើមឆ្នាំ១៩៩២ ខ្លួនត្រូវការយកដីសង់ផ្ទះ ក៏បានប្រាប់ឱ្យឈ្មោះប៉ិច ហុង រុះរើម៉ាស៊ីនអារឈើចេញ តែឈ្មោះប៉ិច ហុង មិនព្រមចេញឡើយ ព្រមទាំងបានជួលកំលាំងមកការពារទៀតផង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១១ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៣ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់លោកសោម ទិត្យ ចុះថ្ងៃទី២៦-១២-១៩៩២ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ប្រគល់ដីលំនៅដ្ឋានទាំងមូលទៅឱ្យលោកសោម ទិត្យ ជាកម្មសិទ្ធិតទៅ ។

៣-ឱ្យឈ្មោះប៉ិច ហុង ព្រមទាំងគ្រួសារជញ្ជូនទ្រព្យសម្បត្តិរបស់ខ្លួនចេញពីដីនេះ ក្នុងរយៈពេល១ខែ ចាប់តាំងពីថ្ងៃប្រកាសសាលក្រមតទៅ ។

៤-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី និង បើកផ្លូវឧទ្ធរណ៍តាមច្បាប់ ។

៥-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី ៧.០០០៛ (ប្រាំពីរពាន់រៀលគត់) ក្នុងនោះមានប្រាក់ចុះបញ្ជីក្តី ប្រាក់ពន្ធហ្វ៊ីង១៨០០៛ "មួយពាន់ប្រាំបីរយរៀល" ប្រាក់រង្វាន់ក្រឡាបញ្ជី ២០០៛ "ពីររយរៀល" ប្រាក់អាជ្ញាធរតុលាការ និងអាជ្ញាធរកណ្តាលចំនួន៥.០០០៛"ប្រាំពាន់រៀល" សរុបប្រាក់ទាំងអស់៧.០០០៛ "ប្រាំពីរពាន់រៀល" ដែលដើមចោទបង់រួចនោះ ឱ្យចុងចម្លើយសងទៅដើមចោទវិញ ក្នុងរយៈពេលផុតកំណត់ប្តឹងឧទ្ធរណ៍២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ១៩៩៥ របស់ឈ្មោះប៊ុច ហុង ,ឈ្មោះហ៊ាន ហាន និងឈ្មោះចេង ហ៊ុម ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១១ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-សំរេចមិនទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះប៊ុច ហុង ។

២-សំរេចចំណាយរឿងនេះ ចេញពីបញ្ជីក្តី ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ១៣.០០០៛ ដែលប្រាក់នេះត្រូវចំណាយលើ : ពន្ធចុះបញ្ជីក្តី , ពន្ធហ្វ៊ីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ,រង្វាន់លើអ្នកប្រគល់ដីកាកោះនិងសន្តិសុខ ១០.០០០៛ ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ហើយបញ្ជូលសំណុំរឿងនេះទៅតុលាការសាម៉ី ដើម្បីអនុវត្ត ។

បានឃើញបណ្តឹងសាទុក្ខចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ របស់ឈ្មោះប៊ុច ហុង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះ ប៊ុច ហុង ។

បានឃើញសារណាតប ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះសោម ទិត្យ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : ចំពោះរឿងនេះ ជារឿងរដ្ឋប្បវេណី ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចចុះ ។

បានស្តាប់ចំលើយរបស់ឈ្មោះប៊ុច ហុង នាពេលសវនាការថា :ដីនេះ ខ្លួនបានទិញត្រឹមត្រូវ

ឆ្នាំ១៩៨៦មករហូតដល់ឆ្នាំ១៩៩០-១៩៩១ ដើមចោទជាជីវដ្ឋចែកឱ្យ ហើយយកកំលាំងមកដេញខ្លួនចេញទៅវិញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសោម យឿន ជាប្រពន្ធប៉ិច ហុង នាពេលជំនុំជំរះថា : ចំពោះរឿងនេះ សាលាឧទ្ធរណ៍ក៏ដូចតុលាការខេត្តកំពង់ស្ពឺ បានធ្វើខុសនីតិវិធី ព្រោះរឿងនេះ ខ្លួនបានប្តឹងឧទ្ធរណ៍ភ្លាម ក្រោយតុលាការខេត្តកំពង់ស្ពឺកាត់ហើយ១០ថ្ងៃ ពាក្យបណ្តឹងខ្លួនយកផ្ទាល់ដៃដាក់ឱ្យលោកកែវ ឆេង ជាចៅក្រម ក្រោយមកថា គ្មានបណ្តឹងទៅវិញ តាមពិតគេបានឃុបឃិតគ្នាធ្វើបាបខ្លួន ហើយកាលពីថ្ងៃទី០៩-៤-១៩៩៣ ខ្លួនបានតវ៉ាដែរ ដូចមានពាក្យបណ្តឹងក្នុងសំណុំរឿងស្រាប់ សូមជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះសោម ទិត្យ នាពេលសវនាការថា : ដីទំនាស់ភូមិ-ឃុំ-ស្រុកបានប្រគល់ឱ្យខ្លួន តាំងពីឆ្នាំ១៩៨៦ មក ពេលប្តឹងផ្តល់ខ្លួនឈ្នះក្តី សាលក្រមចូលស្ថាពរ អនុវត្តរួចរាល់ទៅហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ហេង ពូន ជាមេធាវីការពារឱ្យដើមចោទឈ្មោះសោម ទិត្យ បានលើកឡើងថា : ដីទំនាស់ជាដីរបស់សោម ទិត្យ រដ្ឋអំណាចប្រគល់ឱ្យមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ។ តាមពិតចុងចម្លើយមិនបានប្តឹងឧទ្ធរណ៍ទេ សាលក្រមចូលស្ថាពរអនុវត្តចប់សព្វគ្រប់ទៅហើយ ពេលប្តឹងឧទ្ធរណ៍ខុសច្បាប់នោះ ទើបសាលាឧទ្ធរណ៍បញ្ជូនឱ្យតុលាការកំពង់ស្ពឺអនុវត្ត ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយគូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ ..
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ : គ្មាន ចុះថ្ងៃទី០៧-កញ្ញា-១៩៩៥ របស់ឈ្មោះប៉ិច ហុង, ឈ្មោះសោម យឿន , ឈ្មោះចេង ហ៊ីម បានធ្វើឡើងតាមកំណត់ច្បាប់ ស្របតាមបញ្ញត្តិនៃមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី តុលាការកំពូលអាចលើកយកមកពិនិត្យតាមគតិច្បាប់ ។

- យល់ឃើញថា ការដែលចុងចម្លើយលើកឡើងនៅក្នុងសារណា និងនៅពេលសវនាការនេះថា តុលាការខេត្តកំពង់ស្ពឺ និងសាលាឧទ្ធរណ៍អនុវត្តខុសនីតិវិធីច្បាប់ ពីព្រោះ លោកបានប្តឹងឧទ្ធរណ៍ពីសាលក្រមក្រោយពេលប្រកាសសាលក្រមជាង១០ថ្ងៃប៉ុណ្ណោះ ដោយប្តឹងផ្ទាល់ជាមួយលោក កែវ ឆេង ជាចៅក្រមនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា : "ពាក្យបណ្តឹងតវ៉ាចុះថ្ងៃទី០៩-៤-១៩៩៣ របស់លោកប៉ិច ហុង ,ហ៊ាន ហាន ,និងចេង ហ៊ីម ពុំមានបិទតែម, ពុំមានចុះលេខ ថ្ងៃ ខែ ឆ្នាំ ទទួលលិខិត ពុំមានសំរង់សេចក្តីសុំប្តឹងតវ៉ា, ពុំមានចុះបញ្ជីបណ្តឹងឧទ្ធរណ៍, ពុំមានចុះក្នុងបញ្ជីរាយលិខិតក្នុងសំណុំរឿងផ្ញើជូនសាលាឧទ្ធរណ៍ទេ ប៉ុន្តែចៅក្រមសាលាឧទ្ធរណ៍បានណែនាំឱ្យតុលាការខេត្តកំពង់ស្ពឺចុះបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយ នៅថ្ងៃទី២០-០៣-១៩៩៥ ដែលជាកាលបរិច្ឆេទហួសរយៈពេលប្តឹងឧទ្ធរណ៍ហើយ ។

- ពុំមានភស្តុតាងណា បញ្ជាក់ថា ចុងចម្លើយបានចូលទៅប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ចំពោះមុខលោកចៅក្រម កែវ ឆេង ទេ ពីព្រោះ លោក កែវ ឆេង ជាចៅក្រមជំនុំជំរះ ,លោក សាយ វ៉ាន់ ជាក្រឡាបញ្ជី និង លោក ប៉ុល វន ប្រធានតុលាការ បានចេញសេចក្តីចំលងសាលក្រមលេខ ១១ ចុះថ្ងៃទី២២-៣-១៩៩៣ ដោយមានបញ្ជាក់ថា សាលក្រមនេះ បានចូលជាស្ថាពរចាប់ពីថ្ងៃទី២៣-៦-១៩៩៣ ម្ល៉េះ ដោយភាគីពុំបានចូលមកប្តឹងក្នុងកំណត់ច្បាប់រួចហើយ ។

ដូច្នេះតាមមាត្រា ៧.៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងតាមមាត្រា ១៧៦ និង ១៨០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ បណ្តឹងតវ៉ាពីសាលក្រមរបស់ចុងចម្លើយពុំអាចលើករឿងក្តីមកជំនុំជំរះបានឡើយ

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី ០៧-០៨-១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលពាក្យបណ្តឹងសាទុក្ខលេខ : គ្មាន ចុះថ្ងៃទី ០៧-កញ្ញា-១៩៩៥ របស់ឈ្មោះ ប៉ិច ហុង , ឈ្មោះសោម យឿន,ឈ្មោះចេង ហ៊ីម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៣២២ចុះថ្ងៃទី០៧-០៨-១៩៩៥ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកប៉ិចហុង ចុះនបង់នៅតុលាការកំពូលចំនួន១៩.០០០រៀល

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្លឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០រៀល ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ។